# ចរិយាកូនខ្មែរ

(បទពាក្យ៧)

ខេមរាប្រែថាអ្នកក្សេមក្សាន្ត ល្អល្អះកល្យាណគ្មានអប្រិយ
ល្អកាយល្អចិត្តល្អសំដី ទូទាំងបូរីសុទ្ធបវរ។
អ្នកមានលំអាននៃចរិយា ជាប់ពីដូនតាជាតំណ
អប់រំប្រដៅប្រាប់ខ្មៅស សាងចរិយាធម៌ដ៏ឧត្តម។
មរតកសាសនាពុទ្ធោវាទ បង្ហាញផ្លូវស្អាតមានក្រឹត្យក្រម
ខ្មែរអ្នកពុទ្ធសាសន៍សែនសក្តិសម អ្នកបានអប់រំកាយវាចា។
ទម្លាប់តជាប់ពីបុរាណ កូនខ្មែរគ្រប់ប្រាណគួរដឹងណាំ
ចងចាំលំអាននៃដូនតា ហើយជួយរក្សាអោយគង់វង្ស។
បុព្វបុរសនៃពួកយើង ដួងចិត្តថ្កុំថ្កើងល្អផូរផង់
ឫកពាចរិយាជាប់កាយអង្គ សុភាពស្លូតត្រង់ឥតមានល្អៀង។
ចេះខ្លាចចេះក្រែងឪពុកម្តាយ គោរពអោនកាយមិនកាច់រាង
លំទោនកាយអង្គឥតវេះវៀង ដាក់ចិត្តផ្ចាត់ផ្ចៀងស្តាប់ឱវាទ។
ម៉ែឪស្តីថាទោះស្រាលធ្ងន់ វាយដំដាក់ទណ្ឌប្រាប់បទបាថ
បង្ហាញប្រាយប្រាប់ផ្លូវស្អំស្អាត តាំងចិត្តឱហាតមិនរឹងត្អឹង។
មិនហ៊ានប្រកែកតបតវ៉ា គ្មានចិត្តមោហាប្រកាន់ខឹង
ព្រោះលោកប្រដៅអោយប្រិតប្រឹង គន់គិតសំលឹងរកក្តីគាប់។
ពេលចូលសាលាមិនមូទូ មិនមើលងាយគ្រូចេះគំនាប់
លើកដៃសំពះជាទម្លាប់ រាសីនឹងជាប់ទៅថ្ងៃក្រោយ។
ចេះស្តាប់ពាក្យពេចន៍គ្រូប្រដៅ ប្រាប់ផ្លូវ ស ខ្មៅផ្លូវខ្លាំងខ្សោយ
កំហុសតូចធំពុំបណ្តោយ គ្រូប្រាប់ផ្លូវអោយត្រាប់មិនខ្ជិល។

មិនហ៊ានក្អេងក្អាងអាងទ្រព្យា  ឫកដូចយក្សមារមានចិត្តទមិឡ
ប្រមាថកាតទានសាងមន្ទិល  មើលងាយរមិលគុណគ្រូបា។
ពេលធ្វើដំណើរតាមដងផ្លូវ  ជួនមកជួនទៅជួប យាយតា
ព្រះសង្ឃ ចាស់ទុំ ព្រឹទ្ធាចារ្យ  កុលបុត្រខេមរាត្រូវគោរព។
ដោះមួកដោះឆ័ត្រលំអុតអង្គ  តាំងចិត្តផ្ចូរផង់វៀរឧបទ្រព
ចរចៀសគេចផ្លូវឬត្រូវឈប់  កុំអោយជំពប់ពើបប៉ះពារ។
មិនធ្វើក្រអឺតជំទើតកាយ  ធ្វើឫកលយឆាយដើរកិតកៀរ
ស្មើរចង់បំបុកបែបអ្នកជា  អោយអស់គ្នីគ្នាកោតសរសើរ។
បើជិះយានយន្តម៉ូតូកង់  ត្រូវធាប់បង្អង់រង់ដំណើរ
មិនបើករឹងៗធ្វើគ្រាន់បើ  ក្រែងភ្ជាត់ដំណើររងគ្រោះកម្ម។
ម្យ៉ាងទៀតពេលចូលក្នុងវត្តវ៉ា  កុលបុត្រខេមរាគួរចងចាំ
បុព្វបុរសបានផ្ដែផ្ដាំ  គួរកត់ចំណាំគោរពតាម។
ដោះមួកដាក់ឆ័ត្រជាទម្លាប់  ប្រកាន់អោយខ្ជាប់ពាក្យចាស់ហាម
ឡើងកុដិព្រះសង្ឃចាស់ប្រាប់ប្រាម  ស្បែកជើងជាប់តាមត្រូវដោះចេញ។
ពេលជួបព្រះសង្ឃចង់ចរចា  ប្រណម្យហត្ថាកុំទោរម្នេញ
បន្ទន់ឱនកាយឱ្យពេញលេញ  សាកសួរប្រដេញតាមចម្ងល់។
ចេះប្រើសំដីទន់ពិរោះ  មិនពោលទ្រគោះស្ដីសល់វ៉ល់
ហៅតាមសព្វនាមអោយនិមល  ចង់ផុតឆ្ងៀងឆ្ងល់កុំអៀនខ្មាស់។
តេជគុណ លោកបង ឬលោកប្អូន  លោកក្មួយ លោកកូន អោយបានច្បាស់
តម្រូវតាមវ័យលោកក្មេងចាស់  មិនពិបាកណាស់ពេកទេណ៎ា។
សព្វនាមផ្ទាល់ខ្លួនប្រើជំនួស  ដែលត្រូវប្រើជួស "ខ្ញុំ បាទ ចំា"
គឺ "ខ្ញុំកូណា" និង "កូណា"  នេះជាភាសាសង្ឃសព្ទ។
ចេះបានពីរៀនមានពីរក  ចង់ចេះពាក្យលោកត្រូវរៀនត្រាប់
កុំខ្លាចកុំអៀននាំអន់អាប់  កុំហ៊ានខុសច្បាប់នាំអន្តរាយ។
ក្លាហានខុសក្បួនជួនមានកម្ម  នឹងធ្លាក់ទៅត្រាំថានអបាយ
ហ៊ានស្ដីទ្រគោះជេរនាយអាយ  ទោសពៃរ៍ទាំងឡាយមានមិនខាន។

កូនខ្មែរអ្នកកាន់ពុទ្ធសាសនា ចេះធ្វើកិរិយាល្អកល្យាណ
សក្តិសមជាខ្មែរអ្នកក្រេមក្សាន្ត តជៅសន្តានអ្នកពុទ្ធសាសន៍។
ទំនៀមទំលាប់ល្អសោភី កាន់ប្រពៃណីមិនប្តូរផ្លាស់
បុរាណរក្សាបានល្អណាស់ មិនរិលមិនចាស់ថ្មីជានិច្ច។
យើងកុំនាំគ្នាបែរបោះបង់ ថៃឱ្យត្រូវត្រង់ទោះច្រើនតិច
មិនត្រូវបង្អាប់ត្និះបេះក្តិច ជាន់ឈ្លីពន្លិចអោយសាបសូន្យ។
ទាំងប្រពៃណីស្នេហ៍លោកិយ សម្ព័ន្ធមេត្រីចិត្ត បង-អូន
ទំលាប់ចាស់ទុំតចៅកូន ក្តីស្មោះជាក្បួនជូនដល់គ្នា។
រក្សាប្រពៃណីជាធំ ដួងចិត្តសុខុមគ្រប់វេលា
បើមិនទាន់បានរៀបវិវាហ៍ នឹងមិនបំពារខុសសីលធម៌។
ខ្មាស់ពាក្យថា "ទុំមុនស្រគាល" ជាពាក្យដំនៀលមិនបវរ
អាប់ឱនពូជពង្សវង្សល្អះល្អ នាំល្អក់កករដល់កិត្តិយស។
ផ្ការីករុះរោយមុនរដូវ នាំកាយអាស្រូវខូចកេរ្តិ៍ឈ្មោះ
ទទួលរងពាក្យអសុរស អ្នកផងអោយឈ្មោះថា ខាតលក្ខណ៍។
នេះជាលំអានបុរាណមាន ទុកដូចជាយានចម្លងជាក់
លំអជាតិខ្មែរល្អអន្ទ័ក្ស ចរិយាមានលក្ខណ៍ថ្លៃអនេក។
ខេមរាអ្នកមានចរិយាខ្ពស់ ថ្កើងនាមថ្កើងឈ្មោះថ្កើងសព្វផ្នែក
បើខ្មែរគោរពឥតអល់អែក ខ្មែរនឹងមិនបែកបាត់វប្បធម៌។
ព្រោះខ្មែរជាអ្នកស្គាល់បាបបុណ្យ ស្គាល់ទោសស្គាល់គុណគាប់បវរ
ស្គាល់ខ្ពស់ ស្គាលទាប អាក្រក់ល្អ មានចិត្តស្មោះសរមិនកោងកាច។
មិនជ្រួលមិនជ្រើមរងើមប្ញក មិនវក់វរវីកប្ញកល្ហេចល្ហាច
ប្ញកពាកូនខ្មែរមាំ អង់អាច មិនចេះខ្លបខ្លាចការពារកេរ្តិ៍។✍

*(១២ មករា ២០០៣)*

ភិក្ខុ ស្វាត សាលឿម